ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ក្របខណ្ឌតាមដាន និងវាយតម្លៃលើការអនុវត្តផែនទីបង្ហាញផ្លូវ ការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកកម្ពុជា




រៀបចំដោយ
លេខាធិការដ្ឋានដឹកនាំនិងសម្របសម្រួលការអនុវត្ត
គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥
នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

# មាតិកា


**១. សេចក្តីផ្តើម** ........ ១

**២. ក្របខណ្ឌនៃការតាមដាន និងវាយតម្លៃ** ........ ២

២.១. វិធីសាស្ត្រក្នុងការរៀបចំប្រព័ន្ធតាមដាន និងវាយតម្លៃ ........ ២

២.១.១. ឧបករណ៍សម្រាប់ការតាមដាន និងវាយតម្លៃ ........ ៣

២.១.២. ការតាមដាន និងវាយតម្លៃ ........ ៤

២.២. ការកំណត់សូចនាករសមិទ្ធកម្មគន្លឹះ ........ ៥

២.២.១. គោលការណ៍ក្នុងការកំណត់សូចនាករសមិទ្ធកម្មគន្លឹះ ........ ៥

២.២.២. ការប្រើប្រាស់សូចនាករសមិទ្ធកម្មគន្លឹះ ........ ៦

២.៣. ប្រភពទិន្នន័យ ........ ៧

**៣. ដំណើរការនៃការអនុវត្តក្របខណ្ឌតាមដាន និងវាយតម្លៃ** ........ ៧

៣.១. ការប្រមូលទិន្នន័យ វដ្តនៃការរាយការណ៍ និងប្រភេទនៃរបាយការណ៍ ........ ៧

៣.២. តួនាទីរបស់ក្រសួង ស្ថាប័នទទួលបន្ទុក ........ ៨

**៤. បញ្ហាប្រឈមក្នុងការអនុវត្ត** ........ ៩

**ឧបសម្ព័ន្ធទី១÷** តក្កកម្មអន្តរាគមន៍ (Intervention Logic)

**ឧបសម្ព័ន្ធទី២÷** តារាងសង្ខេបសូចនាករ


លិខិតលេខ ២០៨០/២៤ ក.អ.ក. ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៤ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ស្តីពីសំណើសុំដាក់ឆ្លង "ក្របខណ្ឌតាមដាន និងវាយតម្លៃលើការអនុវត្តផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យយានយន្ត និងអេឡិច-ត្រូនិកកម្ពុជា" ក្នុងកិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (គ.ស.ហ.)

លិខិតលេខ ១៣២៦៥ សហវ.លស.គសហ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការឆ្លើយតបទៅនឹងការស្នើដាក់ឆ្លងសេចក្តីព្រាង "ក្របខណ្ឌតាមដាន និងវាយតម្លៃលើការអនុវត្តផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកកម្ពុជា" ក្នុងកិច្ចប្រជុំ គ.ស.ហ.

# ក្របខណ្ឌតាមដាន និងវាយតម្លៃលើ
# ការអនុវត្តផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកកម្ពុជា

## ១.សេចក្តីផ្តើម

តាមការចង្អុលបង្ហាញរបស់**គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥** (IDP) និង**ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារនិងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ឆ្នាំ២០២១-២០២៣** រាជរដ្ឋាភិបាលបានរៀបចំ**ផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកកម្ពុជា**សម្រាប់ជាមគ្គុទ្ទេសក៍ ក្នុងការជួយតម្រង់ទិស និងពន្លឿនការអភិវឌ្ឍវិស័យទាំងពីរ ដោយបានកំណត់នូវចក្ខុវិស័យរយៈពេលវែង គន្លងអភិវឌ្ឍន៍ច្បាស់លាស់ និងវិធានការជាក់លាក់ ដើម្បីចូលរួមចំណែកក្នុងការជំរុញបរិវត្តកម្មឧស្សាហកម្មកម្ពុជា និងជីវភាពនៃការចូលរួមរបស់កម្ពុជាក្នុងវិស័យសក្តានុពលទាំងពីរទៅក្នុងខ្សែច្រវាក់តម្លៃតំបន់និងសកល ព្រមទាំងជាថ្នាលសម្រាប់គាំទ្រដល់ការងើបឡើងវិញយ៉ាងឆាប់រហ័សនៃសេដ្ឋកិច្ចកម្ពុជា ក្រោយវិបត្តិជំងឺកូវីដ-១៩ និងខណៈដែលវិបត្តិសកលថ្មីៗ បាននិងកំពុងជះឥទ្ធិពលដល់ការអភិវឌ្ឍសង្គម សេដ្ឋកិច្ច ជាបន្តបន្ទាប់។ ផែនទីបង្ហាញផ្លូវនេះ មានចក្ខុវិស័យរយៈពេលវែងក្នុងការប្រែក្លាយកម្ពុជាទៅជា***"មជ្ឈមណ្ឌលប្រមូលផ្តុំសកម្មភាពផលិតគ្រឿងបង្គុំយានយន្ត និងបរិក្ខារអេឡិចត្រូនិក"***។ ដើម្បីឈានទៅសម្រេចបាននូវចក្ខុវិស័យខាងលើ ផែនទីបង្ហាញផ្លូវ ក៏បានកំណត់នូវគន្លងអភិវឌ្ឍន៍ចំនួន ២ រួមមាន÷ ១) កាលានុវត្តភាពបច្ចុប្បន្ន (ឆ្នាំ២០២២-២០២៧) ផ្តោតលើគ្រឿងបង្គុំយានយន្តនិងអេឡិចត្រូនិកសាមញ្ញ, ការផ្គុំដំឡើងគ្រឿងដំឡើងបន្ទាប់បន្សំ, ការផ្គុំដំឡើងទោចក្រយានយន្ត និងឧស្សាហកម្មប្រតិគមន៍ និង ២) គោលដៅរយៈពេលមធ្យម (១០ឆ្នាំបន្ទាប់) ផ្តោតលើគ្រឿងបង្គុំយានយន្តដែលមានលក្ខណៈទំនើបជាងមុន, ការរចនានិងផ្គុំដំឡើងគ្រឿងអេឡិចត្រូនិកដែលមានតម្លៃខ្ពស់ជាងមុន។

ដើម្បីធានាបាននូវការអនុវត្តផែនទីបង្ហាញផ្លូវនេះប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់ស្របតាមការរំពឹងទុក រាជរដ្ឋាភិបាលបានប្រគល់តួនាទីភារកិច្ចឱ្យក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ក.អ.ក.) ដែលមានលេខាធិការដ្ឋានដឹកនាំ និងសម្របសម្រួលការអនុវត្តគោលនយោបាយ IDP (ហៅកាត់ថា លេខាធិការដ្ឋាន IDP) ជាសេនាធិការក្នុងការរៀបចំ និងអនុវត្តក្របខណ្ឌតាមដាន និងវាយតម្លៃការអនុវត្តផែនទីបង្ហាញផ្លូវនេះ។ ក្របខណ្ឌតាមដាន និងវាយតម្លៃនេះ កំណត់យកវិសាលភាពនៃការពិនិត្យតាមដាន និងវាយតម្លៃ លើគន្លងអភិវឌ្ឍន៍ដំណាក់កាលទី១ និងមានគោលបំណងចម្បងចំនួន ២ រួមមាន÷

១)- ផ្តល់ជាមគ្គុទ្ទេសក៍សម្រាប់តម្រង់ទិសការតាមដាន និងវាយតម្លៃការអនុវត្តផែនទីបង្ហាញផ្លូវប្រកបដោយភាពច្បាស់លាស់ ភាពអាចវាស់វែងបាន និងគ្រប់ជ្រុងជ្រោយតាមរយៈការកំណត់ពីអន្តរទំនាក់ទំនងរវាងច្រវាក់លទ្ធផលនៃការអនុវត្តផែនទីបង្ហាញផ្លូវនេះ ស្រប

តាមទ្រឹស្តីបរិវត្តកម្ម (Theory of Change), សំដៅជំរុញប្រសិទ្ធភាព និងប្រសិទ្ធផលនៃការអនុវត្តផែនទីបង្ហាញផ្លូវនេះ

២)- ជាធាតុចូលយ៉ាងសំខាន់សម្រាប់ដោះស្រាយបញ្ហាប្រឈម ធ្វើបច្ចុប្បន្នភាព និងតម្រង់ទិសការអនុវត្តផែនទីបង្ហាញផ្លូវ សម្រាប់គន្លងអភិវឌ្ឍន៍បន្ទាប់ ដើម្បីឆ្ពោះទៅសម្រេចបានពេញលេញនូវចក្ខុវិស័យរយៈពេលវែង។

## ២. ក្របខណ្ឌនៃការតាមដាន និងវាយតម្លៃ

### ២.១. វិធីសាស្ត្រក្នុងការរៀបចំប្រព័ន្ធតាមដាន និងវាយតម្លៃ

ផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកកម្ពុជា ត្រូវបានបង្កើតឡើងដោយផ្អែកលើទ្រឹស្តីបរិវត្តកម្ម ក្នុងការជំរុញការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកកម្ពុជា ស្របតាមគោលនយោបាយ IDP។ ទ្រឹស្តីបរិវត្តកម្មនៃផែនទីបង្ហាញផ្លូវនេះ រួមមាន÷

(១) ចក្ខុវិស័យ÷ ប្រែក្លាយជាមជ្ឈមណ្ឌលប្រមូលផ្តុំសកម្មភាពផលិតគ្រឿងបង្គុំយានយន្ត និងបរិក្ខារអេឡិចត្រូនិក ហើយត្រូវបានអង្គុន់ជាគន្លងអភិវឌ្ឍន៍យ៉ាងច្បាស់លាស់ ចំនួន ២ គឺ ទី១- ផ្តោតលើគ្រឿងបង្គុំយានយន្តនិងអេឡិចត្រូនិកសាមញ្ញ, ការផ្គុំដំឡើងគ្រឿងដំឡើងបន្ទាប់បន្សំ, ការផ្គុំដំឡើងទោចក្រយានយន្ត និងឧស្សាហកម្មប្រតិគមន៍, និង ទី២- ផ្តោតលើគ្រឿងបង្គុំយានយន្តដែលមានលក្ខណៈទំនើបជាងមុន, ការរចនានិងផ្គុំដំឡើងគ្រឿងអេឡិចត្រូនិកដែលមានតម្លៃខ្ពស់ជាងមុន ដោយភ្ជាប់មកជាមួយនូវគោលដៅ ចំនួន ២ គឺ កំណើនការនាំចេញ និងកំណើនចំនួនកម្លាំងពលកម្មក្នុងវិស័យទាំងពីរ ជាលទ្ធផលរយៈពេលវែង ឬផលជះ ក្នុងកម្រិតយុទ្ធសាស្ត្រ,

(២) ផ្នែកទាំង៥ ដែលគាំទ្រដល់គន្លងអភិវឌ្ឍន៍ដំណាក់កាលទី១ (យុទ្ធសាស្ត្រ និងការសម្របសម្រួលអន្តរស្ថាប័ន, ធនធានមនុស្សនិងនវានុវត្តន៍, ហេដ្ឋារចនាសម្ព័ន្ធ, កិច្ចសម្រួលពាណិជ្ជកម្ម, និងបរិយាកាសធុរកិច្ចនិងវិនិយោគ) ជាលទ្ធផលចុងក្រោយ ក្នុងកម្រិតវិស័យ, និង

(៣) វិធានការ និងបង្គោលចរនីមួយៗ ដែលគាំទ្រដល់គន្លងអភិវឌ្ឍន៍ដំណាក់កាលទី១ ជាសកម្មភាពត្រូវអនុវត្តក្នុងកម្រិតបច្ចេកទេស។

ដើម្បីអាចវាស់វែង និងវាយតម្លៃនូវការអនុវត្តផែនទីបង្ហាញផ្លូវឱ្យបានច្បាស់លាស់ ចាំបាច់ត្រូវរៀបចំផ្នែកសំខាន់ៗទាំងបីខាងលើចូលទៅក្នុងរចនាសម្ព័ន្ធនៃប្រព័ន្ធតាមដាន និងវាយតម្លៃ ដូចមានបង្ហាញក្នុងរូបភាពទី១។

***រូបភាពទី១÷ រចនាសម្ព័ន្ធក្នុងប្រព័ន្ធតាមដាន និងវាយតម្លៃ***

| កម្រិត | រចនាសម្ព័ន្ធ និងផ្នែកនៃផែនទីបង្ហាញផ្លូវ | ការរៀបចំក្នុងប្រព័ន្ធតាមដាននិងវាយតម្លៃសម្រាប់គន្លងអភិវឌ្ឍន៍ដំណាក់កាលទី១ | ប្រភេទលទ្ធផល |
|---|---|---|---|
| កម្រិតយុទ្ធសាស្ត្រ | -ចក្ខុវិស័យ (១) គន្លងអភិវឌ្ឍន៍ (២)<br>-គោលដៅ (២) | -គន្លងអភិវឌ្ឍន៍ដំណាក់កាលទី១ (១)<br>-គោលបំណង (៣) | លទ្ធផលរយៈពេលវែង ឬផលជះ |
| កម្រិតវិស័យ | -ផ្នែកគាំទ្រគន្លងអភិវឌ្ឍន៍ដំណាក់-កាលទី១ (៥) | -អន្តរាគមន៍គោលនយោបាយ (៥) | លទ្ធផលចុងក្រោយ |
| កម្រិតបច្ចេកទេស | -វិធានការគាំទ្រគន្លងអភិវឌ្ឍន៍ដំណាក់កាលទី១ (២០) | -វិធានការគោលនយោបាយ (២០) | សកម្មភាព និងលទ្ធផលក្នុងឆ្នាំ |

***រូបភាពទី២÷ ការបំប្លែងផែនទីបង្ហាញផ្លូវ ចូលក្នុងរចនាសម្ព័ន្ធប្រព័ន្ធតាមដាន និងវាយតម្លៃ***






**២.១.១. ឧបករណ៍សម្រាប់ការតាមដាន និងវាយតម្លៃ**

ប្រព័ន្ធតាមដាន និងវាយតម្លៃការអនុវត្តផែនទីបង្ហាញផ្លូវនេះ ប្រើប្រាស់នូវឧបករណ៍ចំនួន ៣ ដូចខាងក្រោម÷

**(១) តក្កកម្មអន្តរាគមន៍ (Intervention Logic)** គឺជាឧបករណ៍បង្ហាញពីរចនាសម្ព័ន្ធគោលនៃទំនាក់ទំនងរវាងវិធានការគោលនយោបាយទាំង ២០, អន្តរាគមន៍គោលនយោបាយទាំង ៥ (Intervention Areas) ជាមួយនឹងគោលបំណងទាំង ៣, គន្លងអភិវឌ្ឍន៍ដំណាក់កាលទី១ នៃផែនទីបង្ហាញផ្លូវ ដោយអនុលោមតាមទ្រឹស្តីបរិវត្តកម្ម។

(២) ក្របខណ្ឌតក្កកម្ម (Log-frame) គឺជាឧបករណ៍ក្នុងទម្រង់ជាតារាងលម្អិត ដែលបង្ហាញនូវគ្រប់វិធានការគោលនយោបាយទាំង២០ ដូចមានចែងក្នុងផែនទីបង្ហាញផ្លូវ, អន្តរាគមន៍គោលនយោបាយទាំង៥, និងគោលបំណងទាំង៣ ។ ការអនុវត្តវិធានការគោលនយោបាយ គឺជាសកម្មភាព និងលទ្ធផល

ក្នុងឆ្នាំ ដែលត្រូវតាមដាននិងវាយតម្លៃក្នុងកម្រិតបច្ចេកទេស, សមិទ្ធកម្មនៃអន្តរាគមន៍គោលនយោបាយ គឺជាលទ្ធផលចុងក្រោយ ដែលត្រូវវាយតម្លៃក្នុងកម្រិតវិស័យ, និងសមិទ្ធកម្មនៃការសម្រេចគោលបំណង គឺជាលទ្ធផលរយៈពេលវែង ឬផលជះ ដែលត្រូវវាយតម្លៃក្នុងកម្រិតយុទ្ធសាស្ត្រ។ ក្របខណ្ឌតក្កកម្ម ជាឧបករណ៍មួយដែលកំណត់ថាតើផែនទីបង្ហាញផ្លូវ នឹងត្រូវវាស់វែង «ដោយរបៀបណា» តាមរយៈការកំណត់នូវសូចនាករសមិទ្ធកម្មគន្លឹះ (KPIs) ដែលមានលក្ខណៈច្បាស់លាស់ និងអាចវាស់វែងបាន។

(៣) ទម្រង់គំរូរបាយការណ៍ (Report Template Format - RTF) គឺជាឧបករណ៍ដែលដាក់បញ្ចូលនូវរាល់វិធានការគោលនយោបាយ ដែលបានកំណត់នៅក្នុងបរិសិដ្ឋទី៣ នៃផែនទីបង្ហាញផ្លូវ។ RTF នឹងត្រូវបានប្រើប្រាស់ដើម្បីប្រមូលព័ត៌មាន និងពិនិត្យអំពីវឌ្ឍនភាពនៃការអនុវត្តវិធានការគោល-នយោបាយទាំង២០ ពីក្រសួង ស្ថាប័ន ទទួលបន្ទុកដឹកនាំអនុវត្ត។ ព័ត៌មានចាំបាច់សម្រាប់វិធានការនីមួយៗនៅក្នុង RTF រួមមាន បង្គោលចរ, ពេលវេលាអនុវត្ត, វឌ្ឍនភាព, ភាគរយនៃការសម្រេចបាន, ការងារដែលបានសម្រេច, បញ្ហាប្រឈម, និងសំណូមពរ។

### ២.១.២. ការតាមដាន និងវាយតម្លៃ

ការកំណត់ការតាមដាន និងវាយតម្លៃឱ្យបានច្បាស់លាស់ ពិតជាមានសារៈសំខាន់ ដើម្បីធានាបាននូវវឌ្ឍនភាព ប្រសិទ្ធភាព សង្គតិភាព និងភាពជោគជ័យនៃការអនុវត្តផែនទីបង្ហាញផ្លូវនេះ ព្រមទាំងជាមូលដ្ឋានដ៏សំខាន់ក្នុងការជំរុញ និងតម្រង់ទិសការអនុវត្តវិធានការដែលមានចែងក្នុងផែនទីបង្ហាញផ្លូវសំដៅធានាការអនុវត្តឱ្យបានទាន់ពេលវេលា និងផ្តល់ផលជះតាមការរំពឹងទុក។ ដំណាក់កាលនៃការតាមដាន និងវាយតម្លៃ ត្រូវបានចែកចេញជា ២ គឺ ដំណាក់កាលតាមដាន និងដំណាក់កាលវាយតម្លៃទៅតាមកម្រិតនិងប្រភាក់លទ្ធផល។

*រូបភាពទី៣÷ ដំណាក់កាលនៃការតាមដាន និងវាយតម្លៃ*



### ក. ការតាមដាន

ការតាមដាន គឺជាដំណើរការនៃការប្រមូល និងការប្រើប្រាស់ព័ត៌មាននិងទិន្នន័យសម្រាប់អង្កេត និងកត់ត្រានូវវឌ្ឍនភាពការអនុវត្តផែនការសកម្មភាពនៃវិធានការដែលបានកំណត់ ស្វែងយល់អំពីបញ្ហាប្រឈម នៅក្នុងអំឡុងពេលកំពុងអនុវត្ត និងបន្តឆ្លើយតបទៅនឹងបញ្ហាប្រឈមទាំងនោះ ដើម្បីធានាការសម្រេចបានប្រកបដោយប្រសិទ្ធភាពនូវអន្តរាគមន៍គោលនយោបាយ, គោលបំណង, គន្លងអភិវឌ្ឍន៍ដំណាក់កាលទី១ របស់ផែនទីបង្ហាញផ្លូវ។ សកម្មភាព និងលទ្ធផលក្នុងឆ្នាំ ព្រមទាំងសូចនាករសមិទ្ធកម្មគន្លឹះនៃវិធានការគន្លឹះមួយចំនួន នឹងត្រូវបានប្រើប្រាស់សម្រាប់ការតាមដាន ហើយនឹងត្រូវរាយការណ៍ជូនគណៈកម្មាធិការប្រតិបត្តិ។

### ខ. ការវាយតម្លៃ

ការវាយតម្លៃ គឺជាដំណើរការនៃការវាយតម្លៃលើការអនុវត្តវិធានការដែលបានដាក់ចេញក្នុងផែនទីបង្ហាញផ្លូវ ដោយប្រើវិធីសាស្រ្តចម្រុះ តាមរយៈការប្រមូល ចងក្រង និងវិភាគទិន្នន័យ និងព័ត៌មាន ដោយធ្វើការវិភាគលើភស្តុតាង (evidence based) ទាំងបែបបរិមាណវិស័យ (quantitative) និងបែបគុណវិស័យ (qualitative) ដើម្បីធានានូវប្រសិទ្ធភាពនិងប្រសិទ្ធផលវឌ្ឍនភាពនៃការអនុវត្ត ដែលអាចយកជាមូលដ្ឋានក្នុងការកែតម្រូវ និងដោះស្រាយរាល់នូវបញ្ហាប្រឈមចំពោះមុខនានា ព្រមទាំងសម្រាប់ជាការតម្រង់ទិសការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកតាមការចាំបាច់។ ទន្ទឹមនេះ ការវាយតម្លៃ អាចប្រមូលធាតុចូលពីវិស័យឯកជន ដែលជាភាគីពាក់ព័ន្ធសំខាន់ ក្នុងការកំណត់មូលដ្ឋាននៃបញ្ហាប្រឈម និងកែតម្រូវវិធានការស្របតាមទិដ្ឋភាពជាក់ស្តែង។ ការវាយតម្លៃត្រូវបានរៀបចំឡើង ដោយគ្របដណ្តប់ផងដែរទៅលើការតាមដាន (សកម្មភាព និងលទ្ធផលក្នុងឆ្នាំ) ដើម្បីឆ្លុះបញ្ចាំងឱ្យបានគ្រប់ជ្រុងជ្រោយអំពីការអនុវត្តវិធានការនិងផែនការសកម្មភាព ទៅនឹងអន្តរាគមន៍គោលនយោបាយ, គោលបំណង, គន្លងអភិវឌ្ឍន៍ដំណាក់កាលទី១ របស់ផែនទីបង្ហាញផ្លូវ។ ច្រវាក់លទ្ធផលនៃសកម្មភាព, លទ្ធផលក្នុងឆ្នាំ, លទ្ធផលចុងក្រោយ និងផលជះ នឹងត្រូវបានប្រើប្រាស់សម្រាប់ការវាយតម្លៃ ហើយនឹងត្រូវរាយការណ៍ជូនកិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (គ.ស.ហ.)។

## ២.២. ការកំណត់សូចនាករសមិទ្ធកម្មគន្លឹះ

### ២.២.១. គោលការណ៍ក្នុងការកំណត់សូចនាករសមិទ្ធកម្មគន្លឹះ

សូចនាករសមិទ្ធកម្មគន្លឹះទាំងអស់ត្រូវបានរៀបចំឡើងផ្អែកតាមគោលការណ៍ SMART (មានភាពជាក់លាក់ Specific, អាចវាស់វែងបាន Measurable, អាចសម្រេចបាន Achievable, មានភាពពាក់ព័ន្ធ Relevant, និងមានពេលវេលាកំណត់ច្បាស់លាស់ Time-bound)។

### ២.២.២. ការប្រើប្រាស់សូចនាករសមិទ្ធកម្មគន្លឹះ

សូចនាករសមិទ្ធកម្មគន្លឹះទាំងអស់មានសរុបចំនួន ៧៦ ដែលត្រូវបានបែងចែកជា ២ កម្រិត រួមមាន÷ ១)- សូចនាករសមិទ្ធកម្មគន្លឹះកម្រិតយុទ្ធសាស្ត្រ ចំនួន ១៧ និង ២)- សូចនាករសមិទ្ធកម្មគន្លឹះកម្រិតវិស័យ ចំនួន ៥៩។ ទន្ទឹមនេះ ក៏មាននូវបង្គោលចរ សរុបចំនួន ៧៩ ផងដែរ។

សូចនាករសមិទ្ធកម្មគន្លឹះកម្រិតយុទ្ធសាស្ត្រ គឺជាសូចនាករបែបបរិមាណវិស័យ ដែលវាស់វែងទៅលើផលជះ នៃផែនទីបង្ហាញផ្លូវ ដោយមើលទៅលើសូចនាករសមិទ្ធកម្មគន្លឹះនៅកម្រិតគោលបំណង។ សូចនាករសមិទ្ធកម្មគន្លឹះកម្រិតវិស័យ គឺជាសូចនាករបែបបរិមាណវិស័យ ដែលវាស់វែងទៅលើលទ្ធផលចុងក្រោយ ដោយមើលទៅលើសូចនាករសមិទ្ធកម្មគន្លឹះនៅកម្រិតអន្តរាគមន៍គោលនយោបាយ។ សូចនាករសមិទ្ធកម្មគន្លឹះកម្រិតវិស័យមួយចំនួន (យ៉ាងច្រើនពីរ នៅក្នុងអន្តរាគមន៍គោលនយោបាយនីមួយៗ) ដែលពាក់ព័ន្ធខ្លាំងនឹងបញ្ហាប្រឈមលើកឡើងដោយវិនិយោគិន និងទៅនឹងការសម្រេចបាននៃវិធានការគន្លឹះ ដែលបានដាក់ចេញសម្រាប់ដោះស្រាយបញ្ហាប្រឈមទាំងនោះ នឹងត្រូវជ្រើសរើសដើម្បីធ្វើការតាមដានរួមគ្នា ជាមួយនឹងសូចនាករកម្រិតបច្ចេកទេស។ សូចនាករកម្រិតបច្ចេកទេស គឺជាសូចនាករបែបគុណវិស័យ (បង្គោលចរ) មានចែងក្នុងបរិសិដ្ឋទី៣ នៃផែនទីបង្ហាញផ្លូវ ដែលវាស់វែងទៅលើសកម្មភាព និងលទ្ធផលក្នុងឆ្នាំ ព្រមទាំងវឌ្ឍនភាពនៃការអនុវត្តវិធានការគោលនយោបាយ ហើយនឹងត្រូវប្រមូលរៀងរាល់ ៦ ខែម្តង។

សូចនាករសមិទ្ធកម្មគន្លឹះកម្រិតវិស័យមួយចំនួន និងសូចនាករកម្រិតបច្ចេកទេសនឹងត្រូវយកមកប្រើ-ប្រាស់ក្នុងការតាមដាន។ ដោយឡែក សូចនាករគ្រប់កម្រិត នឹងត្រូវបានយកមកប្រើប្រាស់ក្នុងការវាយតម្លៃ។

*រូបភាពទី៤÷ កម្រិតនិងការប្រើប្រាស់សូចនាករ*

| កម្រិតនៃសូចនាករ | កម្រិតនៃក្របខណ្ឌកត្តកម្ម | ច្រវាក់លទ្ធផល | ចំនួន |
|---|---|---|---|
| កម្រិតយុទ្ធសាស្ត្រ | គោលបំណង | លទ្ធផលរយៈពេលវែង ឬផលជះ | ១៧ |
| កម្រិតវិស័យ | អន្តរាគមន៍គោលនយោបាយ | លទ្ធផលចុងក្រោយ ឬរយៈពេលមធ្យម | ៥៩ |
| កម្រិតបច្ចេកទេស | វិធានការ | លទ្ធផលក្នុងឆ្នាំ ឬរយៈពេលខ្លី | ៧៩ |

### ២.៣. ប្រភពទិន្នន័យ

ទិន្នន័យដែលនឹងត្រូវយកមកប្រើប្រាស់នៅក្នុងការតាមដាន និងវាយតម្លៃលើសូចនាករសមិទ្ធកម្មគន្លឹះនីមួយៗ អាចមានប្រភព ចំនួន ២ គឺប្រភពទិន្នន័យជាតិ និងប្រភពទិន្នន័យអន្តរជាតិ។ ប្រភពទិន្នន័យជាតិ សំដៅដល់ប្រភពទិន្នន័យរបស់ក្រសួង ស្ថាប័នសាមី។ ដោយឡែក ប្រភពទិន្នន័យអន្តរជាតិ សំដៅលើប្រភពទិន្នន័យដែលអាចទាញយកពីអង្គការអន្តរជាតិនានា។ ប្រភពទិន្នន័យអន្តរជាតិ នឹងត្រូវយកមកប្រើប្រាស់ក្នុងករណីដែលទិន្នន័យជាតិ ពុំអាចរកបាន និងក្នុងករណីយកមកធ្វើការប្រៀបធៀប (Benchmark)។

## ៣. ដំណើរការនៃការអនុវត្តក្របខណ្ឌតាមដាន និងវាយតម្លៃ

### ៣.១. ការប្រមូលទិន្នន័យ វដ្តនៃការរាយការណ៍ និងប្រភេទនៃរបាយការណ៍

ក្រសួង ស្ថាប័ន ដែលស្ថិតក្នុងក្រុមការងារពន្លឿនវិស័យយានយន្ត និងអេឡិចត្រូនិក ត្រូវសហការផ្តល់ ឬបញ្ជូនទិន្នន័យ និងព័ត៌មានប្រចាំឆមាស សម្រាប់ការតាមដានវឌ្ឍនភាព ឱ្យបានត្រឹមដំណាច់សប្តាហ៍ទី១ នៃឆមាសបន្ទាប់ និងត្រូវសហការផ្តល់ ឬបញ្ជូនទិន្នន័យ និងព័ត៌មានប្រចាំឆ្នាំ ស្របតាមវដ្តនៃការរាយការណ៍ឱ្យបានត្រឹមដំណាច់ត្រីមាសទី១ នៃឆ្នាំបន្ទាប់ មកលេខាធិការដ្ឋាន IDP។

ទិន្នន័យ ដែលក្រសួង ស្ថាប័នពាក់ព័ន្ធផ្តល់មកលេខាធិការដ្ឋាន IDPត្រូវជាទិន្នន័យផ្លូវការដែលអាចប្រើប្រាស់បានរបស់ក្រសួង ស្ថាប័នសាមី។ បន្ទាប់ពីទទួលបានទិន្នន័យប្រចាំឆមាស និងឆ្នាំ លេខាធិការ-ដ្ឋាន IDP មានតួនាទីរៀបចំរបាយការណ៍ ២ ប្រភេទ ដោយសហការ និងពិគ្រោះយោបល់ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ រួមមាន÷

- របាយការណ៍ស្តីពីលទ្ធផលតាមដានវឌ្ឍនភាព ក្នុងទម្រង់ជាបទបង្ហាញ ជូនគណៈកម្មាធិការប្រតិបត្តិរៀងរាល់ ៦ ខែ ដោយផ្តោតលើសូចនាករកម្រិតបច្ចេកទេស និងសូចនាករសមិទ្ធកម្មគន្លឹះមួយចំនួនក្នុងកម្រិតវិស័យ
- របាយការណ៍ស្តីពីលទ្ធផលនៃការវាយតម្លៃ ក្នុងទម្រង់ជារបាយការណ៍ស៊ីជម្រៅ ជូនកិច្ចប្រជុំ គ.ស.ហ. រៀងរាល់ ២ ឆ្នាំម្តង ដោយផ្តោតលើសូចនាករគ្រប់កម្រិត។

*រូបភាពទី៥÷ គំនូសបំព្រួញនៃការរាយការណ៍អំពីលទ្ធផលតាមដានវឌ្ឍនភាព*



*រូបភាពទី៦÷ គំនូសបំព្រួញនៃការរាយការណ៍អំពីលទ្ធផលវាយតម្លៃ*




### ៣.២. តួនាទីរបស់ក្រសួង ស្ថាប័នទទួលបន្ទុក

លេខាធិការដ្ឋាន IDP មានតួនាទី÷

– សម្របសម្រួលជាមួយមន្ត្រី នៃក្រសួង ស្ថាប័ន ដែលស្ថិតក្នុងក្រុមការងារពន្លឿនវិស័យយានយន្ត និងអេឡិចត្រូនិកក្នុងការប្រមូលទិន្នន័យសម្រាប់ការតាមដាននិងវាយតម្លៃការអនុវត្តផែនទីបង្ហាញផ្លូវ
– ប្រមូល ចងក្រង ធ្វើសុពលកម្ម និងវិភាគទិន្នន័យសម្រាប់រៀបចំរបាយការណ៍ស្តីពីលទ្ធផលតាមដានវឌ្ឍនភាពនៃការអនុវត្តផែនទីបង្ហាញផ្លូវ ជូនគណៈកម្មាធិការប្រតិបត្តិរៀងរាល់ ៦ ខែ និងរៀបចំរបាយការណ៍ស្តីពីលទ្ធផលវាយតម្លៃរៀងរាល់ ២ ឆ្នាំម្តង ជូន គ.ស.ហ.។

ក្រសួង ស្ថាប័នពាក់ព័ន្ធមានតួនាទី÷

– ក្រសួង ស្ថាប័នទទួលបន្ទុកដឹកនាំ និងអនុវត្តវិធានការ ត្រូវផ្តល់ព័ត៌មានអំពីវឌ្ឍនភាពនៃការអនុវត្តវិធានការប្រចាំឆមាសតាមទម្រង់គំរូរបាយការណ៍ (RTF)
– ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវផ្តល់ទិន្នន័យលើសូចនាករសមិទ្ធកម្មគន្លឹះដូចមានចែងក្នុងឧបសម្ព័ន្ធទី២
– ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ មក ក.អ.គ. ក្នុងករណីមានការផ្តល់ទិន្នន័យយឺតយ៉ាវ ឬមានតម្រូវការកែសម្រួលទិន្នន័យនានា។

## ៤. បញ្ហាប្រឈមក្នុងការអនុវត្ត

ការអនុវត្តយន្តការតាមដាន និងវាយតម្លៃខាងលើនេះ អាចនឹងជួបប្រទះបញ្ហាប្រឈមធំៗ ចំនួន ០៥ រួមមាន ពេលវេលា, ថវិកា, ធនធានមនុស្ស, គុណភាពទិន្នន័យ និងការសម្របសម្រួល÷

- **បញ្ហាក្របខណ្ឌពេលវេលា÷** ដំណើរការនៃការតាមដាន និងវាយតម្លៃរបស់លេខាធិការដ្ឋាន IDP ជួបប្រទះនូវបញ្ហាស្មុគស្មាញច្រើន ដែលអាចប៉ះពាល់ដល់ក្របខណ្ឌពេលវេលាដែលបានគ្រោងទុក។ ទន្ទឹមនេះ ក្រសួង ស្ថាប័នពាក់ព័ន្ធ ចំណាយពេលច្រើនក្នុងការស្វែងយល់អំពីគោលការណ៍ និងការអនុវត្តតួនាទី ភារកិច្ច ដែលបានកំណត់។
- **បញ្ហាធនធានថវិកា÷** ថវិកាសម្រាប់ការអនុវត្តការងារមានកង្វះខាត ដោយសារការស្នើសុំថវិកាសម្រាប់គាំទ្រ ត្រូវផ្អែកទៅលើផែនការសកម្មភាពដែលបានដាក់ចេញដោយក្រសួងស្ថាប័នពាក់ព័ន្ធ។
- **បញ្ហាធនធានមនុស្ស÷** លេខាធិការដ្ឋាន IDP និងក្រសួង ស្ថាប័ន នឹងមានកង្វះខាតនូវមន្ត្រីជំនាញ សម្រាប់គាំទ្រក្នុងការអនុវត្តយន្តការតាមដាន និងវាយតម្លៃ ការកំណត់សូចនាករសមិទ្ធកម្មគន្លឹះសំខាន់ៗពាក់ព័ន្ធ និងការផ្តល់ទិន្នន័យជាដើម។
- **បញ្ហាគុណភាពទិន្នន័យ÷** សូចនាករសមិទ្ធកម្មគន្លឹះសំខាន់ៗមួយចំនួន អាចពុំមានទិន្នន័យសម្រាប់វាយការណ៍ ចំណែកគុណភាពនៃទិន្នន័យដែលមានស្រាប់មួយចំនួន អាចនៅមានកម្រិត ដែលធ្វើឱ្យប៉ះពាល់ដល់ការវិភាគ។
- **បញ្ហាការសម្របសម្រួល÷** ការប្រមូល ចងក្រងទិន្នន័យ ការវិភាគ និងសំយោគតាមវិធីសាស្ត្រគុណវិស័យ និងបរិមាណវិស័យ ជាមួយនឹងការដាក់ចេញនូវវិធានការដោះស្រាយ ព្រមទាំងការរៀបចំរបាយការណ៍តាមដាន និងវាយតម្លៃ អាចត្រូវការកិច្ចសម្របសម្រួលច្រើនក្នុងកម្រិតបច្ចេកទេស ដែលទាមទារឱ្យមានការផ្តល់កិច្ចសហការ និងជួយគាំទ្រពីសំណាក់ថ្នាក់ដឹកនាំគ្រប់កម្រិត។

# ឧបសម្ព័ន្ធទី១៖ តក្កកម្មអន្តរាគមន៍នៃផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកកម្ពុជា ឆ្នាំ២០២២ - ២០២៧



# ឧបសម្ព័ន្ធទី២៖ តារាងសង្ខេបសូចនាករ

| គោលបំណងគោលនយោបាយ/អន្តរាគមន៍គោលនយោបាយ | ល.រ | ឈ្មោះសូចនាករ | និយមន័យសូចនាករ/ការគណនា | ប្រភពទិន្នន័យ | វដ្ត រាយការណ៍ |
|---|---|---|---|---|---|
| **កម្រិតយុទ្ធសាស្ត្រ (១៧)** | | | | | |
| **ការបង្កើនការវិនិយោគក្នុងវិស័យយានយន្ត និងអេឡិចត្រូនិក (៩)** | ១ | ទំហំទុនវិនិយោគក្នុងវិស័យយានយន្ត | ទំហំទុនសរុបនៃគម្រោងវិនិយោគដែលបានចុះបញ្ជីជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងវិស័យយានយន្ត | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ប្រចាំឆ្នាំ |
| | ២ | ទំហំទុនវិនិយោគក្នុងវិស័យអេឡិចត្រូនិក | ទំហំទុនសរុបនៃគម្រោងវិនិយោគដែលបានចុះបញ្ជីជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងវិស័យអេឡិចត្រូនិក | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ប្រចាំឆ្នាំ |
| | ៣ | ចំនួនគម្រោងវិនិយោគក្នុងវិស័យយានយន្ត | ចំនួនគម្រោងវិនិយោគសរុបដែលបានចុះបញ្ជីជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងវិស័យយានយន្ត | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ប្រចាំឆ្នាំ |
| | ៤ | ចំនួនគម្រោងវិនិយោគក្នុងវិស័យអេឡិចត្រូនិក | ចំនួនគម្រោងវិនិយោគសរុបដែលបានចុះបញ្ជីជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងវិស័យអេឡិចត្រូនិក | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ប្រចាំឆ្នាំ |
| | ៥ | ចំណែកនៃធាតុផ្សំក្នុងស្រុកក្នុងការផ្គុំនិងដំឡើងទោចក្រយានយន្តនៅកម្ពុជា | ❖ ទំហំធាតុផ្សំក្នុងស្រុករបស់ក្រុមហ៊ុនផ្គុំនិងដំឡើងទោចក្រយានយន្តចំនួន១០ នៅកម្ពុជា (ដែលត្រូវបានជ្រើសរើសជាប៉ាន់ Sampling) សម្រាប់ការធ្វើអង្កេត) នឹងត្រូវបានប្រើប្រាស់ជា Proxy សម្រាប់វាស់វែងទំហំធាតុផ្សំក្នុងស្រុកប្រើប្រាស់ក្នុងសកម្មភាពផ្គុំនិងដំឡើងទោចក្រយានយន្ត។ (ក្នុងការជ្រើសរើសប៉ាន់ក្រុមហ៊ុនគំរូចំនួន១០ នឹងត្រូវបានជ្រើសរើសដោយផ្អែកលើវិធីសាស្ត្រ Stratified Sampling ដែលបែងចែកចំណាត់ថ្នាក់ក្រុមហ៊ុនផ្គុំនិងដំឡើងទោចក្រយានយន្តជា៣ម្រិត | -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រចាំឆ្នាំ |

| គោលបំណងគោលនយោបាយ/អន្តរាគមន៍គោលនយោបាយ | ល.រ | ឈ្មោះសូចនាករ | និយមន័យសូចនាករ/ការគណនា | ប្រភពទិន្នន័យ | វដ្តរាយការណ៍ |
|---|---|---|---|---|---|
| | | | (ផ្អែកលើទំហំទុន វិនិយោគ) ដោយក្នុងនោះ ជ្រើសរើសក្រុមហ៊ុន ចំនួន ៣ ដែលមានទុនវិនិយោគធំជាងគេ, ចំនួន ៤ ដែលមានទំហំទុនវិនិយោគមធ្យម និង ចំនួន ៣ ដែលមានទំហំទុនវិនិយោគតូចជាងគេ។ ចំពោះក្រុមហ៊ុនផ្គុំនិងដំឡើងទោចក្រយានយន្តចំនួន៤ ដែលមានទំហំទុនវិនិយោគប្រហាក់ប្រហែលនឹងតម្លៃមធ្យមនៃទំហំទុនវិនិយោគសរុប នឹងត្រូវបានចាត់ទុកជាក្រុមហ៊ុនដែលមានទំហំទុនវិនិយោគមធ្យម។)<br><br>វិធីសាស្ត្រគណនា÷<br>⌘ចំណែកនៃទំហំធាតុផ្សំក្នុងស្រុកធៀបនឹងចំណាយថ្លៃដើមផលិតកម្មសរុបក្នុងការផ្គុំនិងដំឡើង ទោចក្រយានយន្តនៅកម្ពុជា គឺជាមធ្យមភាគនៃចំណែកទំហំធាតុផ្សំក្នុងស្រុកធៀបនឹងចំណាយថ្លៃដើមផលិតកម្មសរុបនៃក្រុមហ៊ុនគំរូទាំង១០។<br>ក្នុងនោះ÷<br>⌘ចំណែកនៃទំហំធាតុផ្សំក្នុងស្រុកធៀបនឹងចំណាយថ្លៃដើមផលិតកម្មសរុបរបស់ក្រុមហ៊ុនទី១= ទំហំធាតុផ្សំក្នុងស្រុករបស់ក្រុមហ៊ុនទី១ (LC) / ចំណាយថ្លៃដើមផលិតកម្មសរុបរបស់ក្រុមហ៊ុនទី១ (Total Cost of Production) ដោយ÷ | | |

| គោលបំណងគោលនយោបាយ/អន្តរាគមន៍គោលនយោបាយ | ល.រ | ឈ្មោះសូចនាករ | និយមន័យសូចនាករ/ការគណនា | ប្រភពទិន្នន័យ | វដ្តរាយការណ៍ |
|---|---|---|---|---|---|
| | | | - (LC) = [ចំណាយលើធាតុចូលផលិតកម្មក្នុងស្រុក (M) + ចំណាយជួលកម្លាំងពលកម្មក្នុងស្រុក (L) + ចំណាយផ្សេងៗ (O)]<br><br>*សម្គាល់÷ ចំណាយផ្សេងៗ មានដូចជា ចំណាយថ្លៃទឹក អគ្គិសនី និងប្រតិបត្តិការនានា -ល-។ | | |
| | ៦ | ចំណែកនៃធាតុផ្សំក្នុងស្រុកក្នុងការផ្គុំនិងដំឡើងយានយន្តនៅកម្ពុជា | ❖ទំហំធាតុផ្សំក្នុងស្រុករបស់ក្រុមហ៊ុនផ្គុំនិងដំឡើងយានយន្តចំនួន១០ នៅកម្ពុជា (ដែលត្រូវបានជ្រើសរើសជាប៉ាន់ សម្រាប់ការធ្វើអង្កេត)នឹងត្រូវបានប្រើប្រាស់ជា Proxy សម្រាប់វាស់វែងទំហំធាតុផ្សំក្នុងស្រុកក្នុងសកម្មភាពផ្គុំនិងដំឡើងយានយន្ត។ ក្នុងការជ្រើសរើសប៉ាន់ ក្រុមហ៊ុនគំរូចំនួន១០ នឹងត្រូវបានជ្រើសរើសដោយផ្អែកលើវិធីសាស្ត្រ Stratified Sampling ដែលបែងចែកចំណាត់ថ្នាក់ក្រុមហ៊ុនផ្គុំ និងដំឡើងយានយន្តជា ៣ កម្រិត (ផ្អែកលើទំហំទុនវិនិយោគ) ដោយក្នុងនោះ ជ្រើសរើសក្រុមហ៊ុនចំនួន ៣ ដែលមានទុនវិនិយោគធំជាងគេ, ចំនួន ៤ ដែលមានទំហំទុនវិនិយោគមធ្យម និង ចំនួន ៣ ដែលមាន ទំហំទុនវិនិយោគតូចជាងគេ។ ចំពោះក្រុមហ៊ុនផ្គុំ និងដំឡើងយានយន្តចំនួន៤ ដែលមានទំហំទុនវិនិយោគប្រហាក់ប្រហែល នឹងតម្លៃមធ្យមនៃ ទំហំទុនវិនិយោគសរុប នឹងត្រូវបានចាត់ទុកជាក្រុមហ៊ុនដែលមានទំហំទុនវិនិយោគមធ្យម។ | -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រចាំឆ្នាំ |

| គោលបំណងគោលនយោបាយ/អន្តរាគមន៍គោលនយោបាយ | ល.រ | ឈ្មោះសូចនាករ | និយមន័យសូចនាករ/ការគណនា | ប្រភពទិន្នន័យ | វដ្តរាយការណ៍ |
|---|---|---|---|---|---|
| | | | វិធីសាស្ត្រគណនា÷<br>⁜ចំណែកនៃទំហំធាតុផ្សំក្នុងស្រុកធៀបនឹងចំណាយថ្លៃដើមផលិតកម្មសរុបក្នុងការផ្គុំនិងដំឡើងយានយន្តនៅកម្ពុជា គឺជាមធ្យមភាគនៃចំណែកទំហំធាតុផ្សំក្នុងស្រុកធៀបនឹងចំណាយថ្លៃដើមផលិតកម្មសរុបនៃក្រុមហ៊ុនគំរូទាំង ១០។<br>ក្នុងនោះ÷<br>⁜ចំណែកនៃទំហំធាតុផ្សំក្នុងស្រុកធៀបនឹងចំណាយថ្លៃដើមផលិតកម្មសរុបរបស់ក្រុមហ៊ុនទី១= ទំហំធាតុផ្សំក្នុងស្រុករបស់ក្រុមហ៊ុនទី១ (LC) / ចំណាយថ្លៃដើមផលិតកម្មសរុបរបស់ក្រុមហ៊ុនទី១ (Total Cost of Production) ដោយ÷<br>- (LC) = [ចំណាយលើធាតុចូលផលិតកម្មក្នុងស្រុក (M) + ចំណាយជួលកម្លាំងពលកម្មក្នុងស្រុក (L) + ចំណាយផ្សេងៗ (O)]<br>* សម្គាល់÷ ចំណាយផ្សេងៗ មានដូចជា ចំណាយថ្លៃទឹក អគ្គិសនី និងប្រតិបត្តិការនានា -ល-។ | | |
| | ៧ | ចំណែកនៃធាតុផ្សំក្នុងស្រុកសរុប ដែលបានប្រើប្រាស់ដោយរោងចក្រផ្គុំ និងដំឡើងគ្រឿងអេឡិចត្រូនិក នៅកម្ពុជា | ធាតុចូលផលិតកម្មក្នុងស្រុក និងទំហំធាតុចូលផលិតកម្មសរុបរបស់ក្រុមហ៊ុនផ្គុំនិងដំឡើងគ្រឿងអេឡិចត្រូនិកចំនួន១០ នៅកម្ពុជា (ដែលត្រូវបានជ្រើសរើសជាប៉ាន់សម្រាប់ការធ្វើអង្កេត) នឹងត្រូវបានប្រើប្រាស់ជា Proxy សម្រាប់វាស់វែង (១) ទំហំធាតុចូលផលិតកម្មមានប្រភពពីក្នុងស្រុក និង (២) ទំហំធាតុចូល | -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រចាំឆ្នាំ |

| គោលបំណងគោលនយោបាយ/អន្តរាគមន៍គោលនយោបាយ | ល.រ | ឈ្មោះសូចនាករ | និយមន័យសូចនាករ/ការគណនា | ប្រភពទិន្នន័យ | វដ្តរាយការណ៍ |
|---|---|---|---|---|---|
| | | | ផលិតកម្មសរុប ក្នុងវិស័យអេឡិចត្រូនិក រៀងគ្នា។ ក្នុងការជ្រើសរើសប៉ាន់ ក្រុមហ៊ុនគំរូចំនួន ១០ នឹងត្រូវបានជ្រើសរើសដោយផ្អែកលើវិធីសាស្ត្រ Stratified Sampling ដែលបែងចែកចំណាត់ថ្នាក់ក្រុមហ៊ុនផ្គុំនិងដំឡើងគ្រឿងអេឡិចត្រូនិកជា ៣កម្រិត (ផ្អែកលើទំហំទុនវិនិយោគ) ដោយក្នុងនោះ ជ្រើសរើសក្រុមហ៊ុនចំនួន ៣ ដែលមានទុនវិនិយោគធំជាងគេ, ចំនួន ៤ ដែលមានទំហំទុនវិនិយោគមធ្យម និង ចំនួន ៣ ដែលមានទំហំទុនវិនិយោគតូចជាងគេ។ ចំពោះក្រុមហ៊ុនផ្គុំនិងដំឡើងគ្រឿងអេឡិចត្រូនិកចំនួន៤ ដែលមានទំហំទុនវិនិយោគប្រហាក់ប្រហែលនឹងតម្លៃមធ្យមនៃទំហំទុន វិនិយោគសរុប នឹងត្រូវបានចាត់ទុកជាក្រុមហ៊ុនដែលមានទំហំទុនវិនិយោគមធ្យម។<br>វិធីសាស្ត្រគណនា៖<br>✂ចំណែកនៃទំហំធាតុផ្សំក្នុងស្រុកធៀបនឹងចំណាយថ្លៃដើមផលិតកម្មសរុបក្នុងការផ្គុំនិងដំឡើងគ្រឿងអេឡិចត្រូនិកនៅកម្ពុជា គឺជាមធ្យមភាគនៃចំណែកទំហំធាតុផ្សំក្នុងស្រុកធៀបនឹងចំណាយថ្លៃដើមផលិតកម្មសរុបនៃក្រុមហ៊ុនគំរូទាំង១០។<br>ក្នុងនោះ៖<br>✂ចំណែកនៃទំហំធាតុផ្សំក្នុងស្រុកធៀបនឹងចំណាយថ្លៃដើមផលិតកម្មសរុបរបស់ក្រុមហ៊ុនទី១= ទំហំធាតុផ្សំក្នុងស្រុករបស់ក្រុមហ៊ុនទី១ (LC) / ចំណាយថ្លៃដើមផលិតកម្មសរុបរបស់ | | |

| គោលបំណងគោលនយោបាយ/អន្តរាគមន៍គោលនយោបាយ | ល.រ | ឈ្មោះសូចនាករ | និយមន័យសូចនាករ/ការគណនា | ប្រភពទិន្នន័យ | វដ្តរាយការណ៍ |
|---|---|---|---|---|---|
| | | | ក្រុមហ៊ុនទី១ (Total Cost of Production ) ដោយ÷<br>- (LC) = [ចំណាយលើធាតុចូលផលិតកម្មក្នុងស្រុក (M) + ចំណាយជួលកម្លាំងពលកម្មក្នុងស្រុក (L) + ចំណាយផ្សេងៗ (O)]<br>*សម្គាល់÷ ចំណាយផ្សេងៗ មានដូចជា ចំណាយថ្លៃទឹក អគ្គិសនី និងប្រតិបត្តិការនានា -ល-។ | | |
| | ៨ | ចំណែកនៃចំនួនគម្រោងវិនិយោគក្នុងវិស័យយានយន្ត ដែលបានបោះទីតាំងក្នុងតំបន់សេដ្ឋកិច្ចពិសេស ធៀបទៅនឹងចំនួនគម្រោងវិនិយោគសរុបក្នុងវិស័យយានយន្ត | ផលធៀបនៃ (១) ចំនួនគម្រោងវិនិយោគ ដែលបានចុះបញ្ជីជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (គ.ល.គ) ក្នុងវិស័យយានយន្ត ដែលបានបោះទីតាំងក្នុងតំបន់សេដ្ឋកិច្ចពិសេសទូទាំងប្រទេស (២) ចំនួន គ.ល.គ. សរុបក្នុងវិស័យយានយន្ត | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ប្រចាំឆ្នាំ |
| | ៩ | ចំណែកនៃចំនួនគម្រោងវិនិយោគក្នុងវិស័យអេឡិចត្រូនិក ដែលបានបោះទីតាំងក្នុងតំបន់សេដ្ឋកិច្ចពិសេស ធៀបនឹងចំនួនគម្រោងវិនិយោគសរុបក្នុងវិស័យអេឡិចត្រូនិក | ផលធៀបនៃ (១) ចំនួន គ.ល.គ. ក្នុងវិស័យអេឡិចត្រូនិក ដែលបានបោះទីតាំងក្នុងតំបន់សេដ្ឋកិច្ចពិសេសទូទាំងប្រទេស និង (២) ចំនួន គ.ល.គ. សរុបក្នុងវិស័យអេឡិចត្រូនិក | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ប្រចាំឆ្នាំ |
| **ការបង្កើនការនាំចេញក្នុងវិស័យយានយន្ត** | ១០ | ទំហំនាំចេញក្នុងវិស័យយានយន្ត | ទំហំនាំចេញសរុបក្នុងវិស័យយានយន្ត | -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ/អគ្គនាយក- | ប្រចាំឆ្នាំ |

| គោលបំណងគោលនយោបាយ/អន្តរាគមន៍គោលនយោបាយ | ល.រ | ឈ្មោះសូចនាករ | និយមន័យសូចនាករ/ការគណនា | ប្រភពទិន្នន័យ | វដ្ត រាយការណ៍ |
|---|---|---|---|---|---|
| និងអេឡិចត្រូនិក (៤) | | | | ដ្ឋានគយ និងរដ្ឋាករកម្ពុជា<br>-ក្រសួងពាណិជ្ជកម្ម | |
| | ១១ | ទំហំនាំចេញក្នុងវិស័យអេឡិចត្រូនិក | ទំហំនាំចេញសរុបក្នុងវិស័យអេឡិចត្រូនិក | -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ/អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា<br>-ក្រសួងពាណិជ្ជកម្ម | ប្រចាំឆ្នាំ |
| | ១២ | ចំណែកនៃទំហំនាំចេញក្នុងវិស័យយានយន្តធៀបនឹងទំហំនាំចេញសរុបក្នុងវិស័យកម្មន្តសាល | ផលធៀបនៃ (១) ទំហំនាំចេញក្នុងវិស័យយានយន្ត និង (២)ទំហំនាំចេញសរុបក្នុងវិស័យកម្មន្តសាល | -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ/អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា<br>-ក្រសួងពាណិជ្ជកម្ម | ប្រចាំឆ្នាំ |
| | ១៣ | ចំណែកនៃទំហំនាំចេញក្នុងវិស័យអេឡិចត្រូនិកធៀបនឹងទំហំនាំចេញសរុបក្នុងវិស័យកម្មន្តសាល | ផលធៀបនៃ (១) ទំហំនាំចេញក្នុងវិស័យអេឡិចត្រូនិក និង (២) ទំហំនាំចេញសរុបក្នុងវិស័យកម្មន្តសាល | -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ/អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា<br>-ក្រសួងពាណិជ្ជកម្ម | ប្រចាំឆ្នាំ |
| ការបង្កើនចំនួនកម្លាំងពលកម្មក្នុងវិស័យយានយន្ត និងអេឡិចត្រូនិក (៤) | ១៤ | ចំនួនការងារក្នុងវិស័យយានយន្ត | ចំនួនកម្លាំងពលកម្មដែលទទួលបានការងារក្នុងវិស័យយានយន្ត។ ទិន្នន័យនេះអាចទទួលបានពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយស្រង់យកតួលេខចំនួនការងារដែលចុះបញ្ជីក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមពាក់ព័ន្ធវិស័យការងារ (LACMS) ក្នុងវិស័យយានយន្ត។ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ប្រចាំឆ្នាំ |
| | ១៥ | ចំនួនការងារក្នុងវិស័យអេឡិចត្រូនិក | ចំនួនកម្លាំងពលកម្មដែលទទួលបានការងារក្នុងវិស័យអេឡិចត្រូនិក។ ទិន្នន័យនេះអាច | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ប្រចាំឆ្នាំ |

| គោលបំណងគោលនយោបាយ/អន្តរាគមន៍គោលនយោបាយ | ល.រ | ឈ្មោះសូចនាករ | និយមន័យសូចនាករ/ការគណនា | ប្រភពទិន្នន័យ | វដ្តរាយការណ៍ |
|---|---|---|---|---|---|
| | | | ទទួលបានពីក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ដោយស្រង់យកតួលេខចំនួនការងារដែលចុះបញ្ជីក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមពាក់ព័ន្ធវិស័យការងារ (LACMS) ក្នុងវិស័យអេឡិចត្រូនិក។ | | |
| | ១៦ | ចំណែកនៃចំនួនការងារ ក្នុងវិស័យយានយន្ត ធៀបនឹងចំនួនការងារសរុបក្នុងវិស័យកម្មន្តសាល | ផលធៀបនៃ (១) ចំនួនការងារក្នុងវិស័យយានយន្ត និង (២) ចំនួនការងារសរុបក្នុងវិស័យកម្មន្តសាល។ និយមន័យនៃវិស័យកម្មន្តសាល នឹងត្រូវអនុលោមតាមនិយមន័យចំណាត់ថ្នាក់ស្តង់ដារវិស័យសេដ្ឋកិច្ចកម្ពុជា (ច.ស.វ.ក.) ផ្តល់ដោយក្រសួងផែនការ។ **ចំនួនកម្លាំងពលកម្មដែលទទួលបានការងារក្នុងវិស័យយានយន្ត ដោយស្រង់យកតួលេខចំនួនការងារដែលចុះបញ្ជីក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមពាក់ព័ន្ធវិស័យការងារ (LACMS) ក្នុងវិស័យយានយន្ត។* | ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ | ប្រចាំឆ្នាំ |
| | ១៧ | ចំណែកនៃចំនួនការងារក្នុងវិស័យអេឡិចត្រូនិក ធៀបនឹងចំនួនការងារសរុបក្នុងវិស័យកម្មន្តសាល | ផលធៀបនៃ (១) ចំនួនការងារ ក្នុងវិស័យអេឡិចត្រូនិក និង (២) ចំនួនការងារសរុបក្នុងវិស័យកម្មន្តសាល។ និយមន័យនៃវិស័យកម្មន្តសាល នឹងត្រូវអនុលោមតាមនិយមន័យចំណាត់ថ្នាក់ស្តង់ដារវិស័យសេដ្ឋកិច្ចកម្ពុជា (ច.ស.វ.ក.) ផ្តល់ដោយក្រសួងផែនការ។ **ចំនួនកម្លាំងពលកម្មដែលទទួលបានការងារក្នុងវិស័យអេឡិចត្រូនិក ដោយស្រង់យកតួលេខចំនួនការងារដែលចុះបញ្ជីក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមពាក់ព័ន្ធវិស័យការងារ (LACMS) ក្នុងវិស័យអេឡិចត្រូនិក។* | ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ | ប្រចាំឆ្នាំ |

| គោលបំណងគោលនយោបាយ/អន្តរាគមន៍គោលនយោបាយ | ល.រ | ឈ្មោះសូចនាករ | និយមន័យសូចនាករ/ការគណនា | ប្រភពទិន្នន័យ | វដ្តរាយការណ៍ |
|---|---|---|---|---|---|
| **កម្រិតវិស័យ (៥៩)** | | | | | |
| **បរិយាកាសធុរកិច្ច និងវិនិយោគ (១៦)** | ១៨ | ចំនួនក្រុមហ៊ុនក្នុងវិស័យយានយន្ត ដែលត្រូវបានជួប | ចំនួនក្រុមហ៊ុនសរុបក្នុងវិស័យយានយន្តដែលត្រូវបានជួប | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ប្រចាំឆ្នាំ |
| | ១៩ | ចំនួនក្រុមហ៊ុនក្នុងវិស័យអេឡិចត្រូនិកដែលត្រូវបានជួប | ចំនួនក្រុមហ៊ុនសរុបក្នុងវិស័យអេឡិចត្រូនិកដែលត្រូវបានជួប | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ប្រចាំឆ្នាំ |
| | ២០ | ទំហំទុនវិនិយោគក្នុងវិស័យយានយន្តក្នុងតំបន់សេដ្ឋកិច្ចពិសេសដែលត្រូវបានកំណត់ជាចង្កោមវិស័យយានយន្ត | ទំហំទុនវិនិយោគសរុបរបស់ គ.ល.គ. ក្នុងវិស័យយានយន្ត ដែលបានបោះទីតាំងក្នុងតំបន់សេដ្ឋកិច្ចពិសេស ដែលត្រូវបានកំណត់ជាចង្កោមវិស័យយានយន្ត(១. តំបន់សេដ្ឋកិច្ចពិសេសសានកូប៉ោយប៉ែត, ២.តំបន់សេដ្ឋកិច្ចពិសេសរ៉ូយ៉ាល់គ្រុប ប៉ោយប៉ែត, និង ៣.តំបន់សេដ្ឋកិច្ចពិសេស អ៊ិនធើវៀ អ្នកម្ហូបាល អ៊ិនដាសស្ទ្រី ខមផ្លេកស៍) | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ប្រចាំឆ្នាំ |
| | ២១ | ទំហំទុនវិនិយោគក្នុងវិស័យអេឡិចត្រូនិកក្នុងតំបន់សេដ្ឋកិច្ចពិសេស ដែលត្រូវបានកំណត់ជាចង្កោមវិស័យអេឡិចត្រូនិក | ទំហំទុនវិនិយោគសរុបរបស់ គ.ល.គ. ក្នុងវិស័យអេឡិចត្រូនិក ដែលបានបោះទីតាំងក្នុងតំបន់សេដ្ឋកិច្ចពិសេស ដែលត្រូវបានកំណត់ជាចង្កោមវិស័យអេឡិចត្រូនិក(១. តំបន់សេដ្ឋកិច្ចពិសេសស្វាយរៀង ហ្គីហ្គាវីសស៍, ២.តំបន់សេដ្ឋកិច្ចពិសេសរ៉ូយ៉ាល់គ្រុប ភ្នំពេញ) | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ប្រចាំឆ្នាំ |
| | ២២ | ទំហំនាំចេញក្នុងវិស័យយានយន្ត ពីតំបន់សេដ្ឋកិច្ចពិសេសដែលត្រូវបានកំណត់ជាចង្កោមវិស័យយានយន្ត | ទំហំនាំចេញក្នុងវិស័យយានយន្តរបស់ គ.ល.គ. ពីតំបន់សេដ្ឋកិច្ចពិសេស ដែលត្រូវបានកំណត់ជាចង្កោមវិស័យយានយន្ត(១. តំបន់សេដ្ឋកិច្ចពិសេសសានកូប៉ោយប៉ែត, ២. តំបន់សេដ្ឋកិច្ចពិសេសរ៉ូយ៉ាល់គ្រុប ប៉ោយប៉ែត, និង ៣. | -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>-ក្រសួងពាណិជ្ជកម្ម | ប្រចាំឆ្នាំ |

| គោលបំណងគោលនយោបាយ/អន្តរាគមន៍គោលនយោបាយ | ល.រ | ឈ្មោះសូចនាករ | និយមន័យសូចនាករ/ការគណនា | ប្រភពទិន្នន័យ | វដ្តរាយការណ៍ |
| --- | --- | --- | --- | --- | --- |
| | | | តំបន់សេដ្ឋកិច្ចពិសេស អ៊ិនធើវៀ អូតូម៉ូបាល អ៊ិនដាសស្ទ្រី ខមផ្លេកស៍) | | |
